ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រម

នស/ រកម/០៩៩៨/០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ភាគទី ១

## បទបញ្ញត្តិនៃច្បាប់ហិរញ្ញវត្ថុកែតម្រូវ

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

---

---

## ជំពូកទី ៤

## បទបញ្ញត្តិស្តីពីពន្ធនិងអាករ

### ផ្នែកទី ១

### បទបញ្ញត្តិស្តីពីទោសទណ្ឌដាក់និងនីតិមូលដ្ឋានកំណត់ពន្ធនិងការត្រួតពិនិត្យ

មាត្រា ៨.-

លើកលែងតែពន្ធប្រថាប់ត្រា ពន្ធតែមប្រ៍ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ការមិនបានបង់ ការបង់មិនគ្រប់ ឬការបង់យឺតនូវប្រភេទពន្ធ ឬអាករដែលប្រមូលដោយនាយកដ្ឋាន ពន្ធដារ ត្រូវបង់បន្ថែមនូវការប្រាក់យឺតយ៉ាវ ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត ។

មាត្រា ៩.-

អត្រាការប្រាក់យឺតយ៉ាវមានចំនួន ២% ក្នុងមួយខែ ដោយគិតលើចំនួនទឹកប្រាក់ពន្ធដែលអ្នកជាប់ពន្ធត្រូវបង់បន្ថែមឬលើចំនួនប្រាក់ពន្ធបង់ដោយយឺតយ៉ាវ ។

មាត្រា ១០.-

ការប្រាក់យឺតយ៉ាវត្រូវគិតចាប់ពីថ្ងៃទី ០១ នៃខែបន្ទាប់ដែលជាខែត្រូវបង់ពន្ធ ។ ចំពោះពន្ធលើប្រាក់ចំណេញ ដែលត្រូវបានបង្កើតឡើងតាមលក្ខខណ្ឌកំណត់ក្នុងមាត្រា២១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ចំណុចផ្តើមនៃការគិតការប្រាក់យឺតយ៉ាវគឺនៅថ្ងៃទី ០១ នៃខែបន្ទាប់ ដែលជាខែផុតរយៈពេលកំណត់សំរាប់ការដាក់លិខិតប្រកាសលទ្ធផលប្រចាំឆ្នាំ ។

មាត្រា ១១.-

ការគិតគូរការប្រាក់យឺតយ៉ាវត្រូវឈប់គិតឬមួយនៅថ្ងៃចុងក្រោយនៃខែ ដែល

អគ្គនាយកដ្ឋាន ពន្ធដារ

បានផ្ញើលិខិត ជូនដំណឹងស្ដីពីការកំណត់ពន្ធឡើងវិញឬមួយនៅថ្ងៃចុងក្រោយ នៃខែដែលបានដាក់លិខិតប្រកាសពន្ធ ។

មាត្រា ១២.-

១- ក្នុងរយៈពេលកំណត់ ការមិនបានដាក់លិខិតប្រកាសពន្ធដែលមានការបញ្ជាក់នូវ ចំណែកខុកសំរាប់កំណត់ឬគណនាប្រាក់ពន្ធឬអាករណាមួយ ដែលប្រមូលដោយនាយកដ្ឋានពន្ធដារនោះ ចំនួនប្រាក់ពន្ធដែលបានមកពីលិខិតប្រកាសពន្ធ ដែលដាក់យឺតយ៉ាវ ត្រូវបូកបន្ថែមលើការប្រាក់យឺតយ៉ាវ ដូចមានចែងក្នុង មាត្រា ៩ ចំនួន ១០% ទៀតនៃចំនួនប្រាក់ពន្ធ ។

២- ការបន្ថែមចំពោះចំណុច ១ ត្រូវឡើងដល់ :

- ២៥% -កាលបើឯកសារបានដាក់ហួសរយៈពេលកំណត់ ១៥ថ្ងៃ បន្ទាប់ពីបានទទួល លិខិតរំលឹកដែលបញ្ជាក់ពីកាតព្វកិច្ចត្រូវបំពេញក្នុងរយៈពេលនេះ
- ៤០% ប្រសិនបើពុំបានដាក់ឯកសារណាមួយ ។

មាត្រា ១៣.-

ក្នុងករណីដែលលិខិតប្រកាសបង្ហាញអោយឃើញថា មូលដ្ឋានកំណត់ពន្ធឬចំណែកសំរាប់គណនាប្រាក់ពន្ធមានលក្ខណៈមិនគ្រប់គ្រាន់ មិនពិតប្រាកដ ឬមិនពេញលេញ ដែលកើតឡើងដោយអចេតនានោះ ចំនួនប្រាក់ពន្ធត្រូវបង់បន្ថែមដោយអ្នកជាប់ពន្ធ ត្រូវបូកបន្ថែមនូវការប្រាក់យឺតយ៉ាវដូចមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ ។ ចំនួនប្រាក់បន្ថែមនេះត្រូវឡើងដល់ ៤០% បន្ថែមលើការប្រាក់យឺតយ៉ាវ ប្រសិនបើកំហុសខាងលើនេះត្រូវបានប្រព្រឹត្តដោយចេតនា ។

មាត្រា ១៤.-

កាលបើអ្នកជាប់ពន្ធបានបង្ហាញអោយដឹង ដោយការកត់ត្រាយ៉ាងច្បាស់លាស់លើលិខិតប្រកាសពន្ធ លើលិខិតស្នាម ឬលើលិខិតដែលជាឧបសម្ព័ន្ធ ភ្ជាប់ជាមួយនូវមូលហេតុខាងផ្លូវច្បាប់ ឬខាងហេតុការណ៍ដែលអ្នកជាប់ពន្ធមិនបាន កត់ត្រានូវចំណែកសំរាប់កំណត់ពន្ធទាំងអស់ឬចំណែកណាមួយឬក៏បានផ្ដល់ចំពោះចំណែកទាំងនេះ នូវការបញ្ជាក់ដែលនាំអោយមានការកំណត់ពន្ធដោយ បន្ទុរបន្ថយ ឬការកាត់ កងពន្ធដែលត្រូវបានទទួលស្គាល់ ពេលក្រោយថាមិនសមហេតុផលនោះ ការកំណត់ពន្ធឡើងវិញចំពោះករណីទាំងនេះ មិននាំអោយមានការអនុវត្តនូវការបង់ការប្រាក់យឺតយ៉ាវ ដូចមានចែងក្នុងមាត្រា ៨ . និងមាត្រា ៩ ឡើយ ។

មាត្រា ១៥.-

ការប្រាក់យឺតយ៉ាវនិងប្រាក់បន្ថែមមិនត្រូវអនុវត្តទេ កាលបើការខុះ

ខាតអំពីតួលេខប្រកាសពន្ធ មិនលើសពី ១ភាគ១០ នៃមូលដ្ឋានកំណត់ពន្ធ បន្ទាប់ពីមានការកំណត់ពន្ធឡើងវិញ ។

**មាត្រា ១៦.-**

ត្រូវបានលុបចោលដោយបទបញ្ញត្តិច្បាប់នេះនូវ ៖

- មាត្រា ១៤ នៃអនុក្រឹត្យលេខ ០៧ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩១ ស្តីពី ពន្ធសត្តឃាត
- មាត្រា ២៣ និងមាត្រា ២៤ ជំពូក ៥ នៃក្រឹត្យច្បាប់លេខ ២២ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធប៉ាតង់
- មាត្រា ១៨ និងមាត្រា ១៩ នៃក្រឹត្យច្បាប់លេខ ២៤ ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធលើទំនិញក្នុងប្រទេស
- មាត្រា ៥៧ មាត្រា ៥៩ និង ចំណុច ១ នៃមាត្រា ៦០ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

## ផ្នែកទី ២

## បទបញ្ញត្តិស្តីពីការកែប្រែពន្ធលើទំនិញក្នុងប្រទេស ជាអាករពិសេសលើទំនិញមួយចំនួន

**មាត្រា ១៧.-**

ចាប់ពីថ្ងៃប្រកាសអោយប្រើច្បាប់នេះ ពន្ធលើទំនិញក្នុងប្រទេសដែលបានបង្កើតឡើងដោយក្រឹត្យច្បាប់ លេខ ២៤ក្រច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ត្រូវហៅថា " អាករពិសេសលើទំនិញមួយចំនួន " វិញ ដូចមានចែងក្នុងផ្នែកទី ២ ជំពូកទី ៤ នៃ ច្បាប់នេះ ។

**មាត្រា ១៨.-**

អត្រាអាករពិសេសលើទំនិញមួយចំនួន ដែលពីមុនឡើងដល់ ៥០% ទៅតាមក្រឹត្យច្បាប់ដូចយោងខាងលើ ត្រូវបន្ថយអោយមកនៅត្រឹមអត្រាពីរដូចតទៅ ៖

- ២០% សំរាប់គ្រប់ផលិតផលតេលសិលា
- ១០% សំរាប់គ្រប់ផលិតផលផ្សេងទៀត ។

## មាត្រា ១៩.-

ត្រូវជាប់អាករពិសេសលើទំនិញមួយចំនួន ទោះបីនាំចូលឬផលិតនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ នូវ ៖

១- ផលិតផលប្រេងកាត :

- ប្រេងសាំងស៊ុបពែរ ឬធម្មតា សំរាប់យានយន្ត
- ប្រេងម៉ាស៊ូត

២- ភេសជ្ជៈ :

- ទឹកមានជាតិឧស្ម័ន មានដាក់ស្ករ ឬក៏សារជាតិផ្អែមផ្សេងទៀត ឬគ្រឿងក្រអូប និង ភេសជ្ជៈដទៃទៀតដែលគ្មានជាតិស្រា លើកលែងតែទឹក និងទឹកមិណេរ៉ាល់ ហើយនិង ទឹកដមផ្លែឈើ ឬ ទឹកដមបន្លែ ។
- ស្រាបៀរ
- ស្រាទំពាំងបាយជូរស្រស់រួមទាំងស្រាទំពាំងបាយជូរដែលមានបន្ថែមជាតិស្រា
  ស្រាវែមុតនិងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិនិងសារជាតិក្រអូប
- ភេសជ្ជៈមេរ៉ែផ្សេងទៀត
- អាល់កុលអេទីលីកសុទ្ធដែលមានកំរិតជាតិស្រាក្នុងឯកតាចំណុះពី៨០% នៃចំណុះ ឬ លើសពីនេះ និងអាល់កុលអេទីលីក ហើយនិងភេសជ្ជៈមានជាតិស្រាដែលបាត់បង់កំរិតស្រាដើមរបស់វា ។
- អាល់កុលអេទីលីកបាត់បង់ធាតុសុទ្ធ ដែលមានកំរិតជាតិស្រាក្នុងឯកតាចំណុះ ៨០% នៃចំណុះ និងភេសជ្ជៈមានជាតិស្រា ភេសជ្ជៈស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃស្រាផ្សំក្នុងប្រភេទដែលប្រើសំរាប់ផលិតភេសជ្ជៈ ។

៣- បារី បារីស៊ីហ្គា គ្រប់ប្រភេទ ។

## មាត្រា ២០.-

ផលិតផលដូចតទៅ លែងត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនទៀតហើយ :

- ថ្នាំជក់មិនកែច្នៃ
- ការ៉េម
- គ្រាប់ឈូក

មាត្រា ២១._

មូលដ្ឋានកំណត់អាករពិសេសលើទំនិញមួយចំនួន ចំពោះ :

១_ ផលិតផលនាំចូល គឺតំលៃក្នុងគយនៃផលិតផលនាំចូលបូកបន្ថែមពន្ធនិងអាករដែលត្រូវបង់នាពេលនាំចូល លើកលែងតែអាករពិសេសខ្លួនឯងនេះនិងអាករប្រើប្រាស់ដែលត្រូវបង់នាពេលនាំចូល ។

២_ ផលិតផលធ្វើនៅព្រះរាជាណាចក្រកម្ពុជា គឺថ្លៃលក់កត់ត្រាក្នុងវិក័យបត្ររបស់អ្នកធ្វើដែលគិត បញ្ចូលទាំងសោហ៊ុយនិងអាករគ្រប់មុខ លើកលែងតែអាករពិសេសខ្លួនឯងនេះ និងអាករលើផលរបរ ។

មាត្រា ២២._

ត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនដែលបានចែងក្នុងមាត្រា ១៩ ៖

១_ ចំពោះទំនិញនាំចូល គឺគ្រប់ការដាក់ទំនិញអោយប្រើប្រាស់នៅ លើដែនដៃប្រទេសជាតិទៅតាមន័យនៃពាក្យរបស់គយ ។

២_ ចំពោះទំនិញផលិតនៅព្រះរាជាណាចក្រកម្ពុជា គឺគ្រប់ការប្រគល់ទំនិញដោយគិតទាំងការប្រគល់ឱ្យដោយឥតយកថ្លៃដែលបានធ្វើឡើងតាមផ្លូវច្បាប់ ឬតាមហេតុការណ៍ពិត នៅលើដែនដៃប្រទេសជាតិ ។

ដោយឡែកត្រូវជាប់អាករពិសេសលើទំនិញមួយចំនួនផងដែរ នូវទំនិញដែលអ្នកធ្វើ ឬផលិតករកាត់យកសំរាប់តម្រូវការផ្ទាល់ខ្លួន សំរាប់តម្រូវការរបស់បុគ្គលិក ឬសំរាប់តម្រូវការរបស់តតិយជន ។

មាត្រា ២៣._

អាករពិសេសលើទំនិញមួយចំនួន ត្រូវបង់ដោយ :

១_ អ្នកនាំចូល ឬអ្នកកាន់កាប់ទំនិញនៅព្រះរាជាណាចក្រកម្ពុជា ចំពោះទំនិញដែលមានដើមកំណើតពីក្រៅ ។

២_ ផលិតករ ឬអ្នកធ្វើ ចំពោះទំនិញផលិត ឬធ្វើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៤._

អ្នកជាប់អាករពិសេសលើទំនិញមួយចំនួន ត្រូវកាន់បញ្ជីពិសេសមួយដែលបង្ហាញឱ្យឃើញច្បាស់នូវ ប្រភេទ បរិមាណ គុណភាព តម្លៃ ៖

១_ ចំពោះការនាំចូល និងការបញ្ចូលផលិតផល ទោះបីផលិតផលទាំងនេះមានដើមកំណើត ពីណាក្តី :

- លេខនិងកាលបរិច្ឆេទនៃប្រតិវេទន៍នាំចូល ឈ្មោះការិយាល័យគយដែលយកទំនិញចេញ កាលបរិច្ឆេទទទួល

- បរិមាណ ទម្ងន់ និងប្រភេទនៃទំនិញនាំចូល
- តម្លៃកត់ត្រាក្នុងវិក័យបត្រនិងមូលដ្ឋានសំរាប់កំណត់អាករពិសេសលើទំនិញមួយចំនួន
- កាលបរិច្ឆេទនិងលេខបង្កាន់ដៃបង់ប្រាក់បញ្ជីពិសេសត្រូវតែមានចុះលេខទំព័រ និង ចុះហត្ថលេខាបញ្ជាក់ជាមុនដោយនាយកទីចាត់ការគយ ឬអ្នកតំណាងដែលមានសិទ្ធិប្រទាន ។

២. ចំពោះទំនិញផលិតឬធ្វើនៅព្រះរាជាណាចក្រកម្ពុជា :

- ស្តុកនៅថ្ងៃទី ៣១ ធ្នូ នៃឆ្នាំនីមួយៗ
- ការកត់ត្រាការធ្វើទំនិញពីមួយថ្ងៃទៅមួយថ្ងៃ
- ការបញ្ចេញទំនិញក៏ត្រូវធ្វើការកត់ត្រាពីមួយថ្ងៃទៅមួយថ្ងៃដែរ ។

បញ្ជីពិសេសត្រូវតែមានចុះលេខទំព័រនិងចុះហត្ថលេខាបញ្ជាក់ជាមុនដោយប្រធាននាយកដ្ឋានពន្ធដារ ឬអ្នកតំណាងដែលមានសិទ្ធិប្រទាន ។

## មាត្រា ២៥.-

ចំពោះទំនិញផលិតឬធ្វើនៅព្រះរាជាណាចក្រកម្ពុជា អ្នកជាប់អាករពិសេសលើទំនិញមួយចំនួន ត្រូវជូនលិខិតប្រកាសពន្ធយ៉ាងយឺតបំផុតនៅថ្ងៃទី ១០ នៃខែនីមួយៗ អោយទៅផ្នែកពន្ធដារ ដោយមានបញ្ជាក់អំពី មូលដ្ឋានកំណត់អាករ ដែលជាលទ្ធផលនៃប្រតិបត្តិការដែលបានសំរេចក្នុងខែមុន ។

លិខិតប្រកាសត្រូវមានកត់ត្រាបញ្ជាក់អំពីចំនួនប្រាក់អាករពិសេសលើទំនិញមួយចំនួនដែលត្រូវបង់ និងត្រូវបង់ភ្លាមនាពេលដាក់លិខិតប្រកាសពន្ធ ។

## មាត្រា ២៦.-

អាករពិសេសលើទំនិញមួយចំនួន ចំពោះទំនិញនាំចូលត្រូវប្រមូលនាពេលនាំចូលដោយអង្គភាពគយ ក្នុងល័ក្ខខ័ណ្ឌនិងតាមបទបញ្ញត្តិដូចគ្នានឹងពន្ធគយនិងអាករប្រើប្រាស់ ។

## មាត្រា ២៧.-

បុគ្គលទាំងឡាយដែលលក់ផលិតផលស្ថិតក្នុងដែនអនុវត្តន៍នៃអាករពិសេសលើទំនិញមួយចំនួន ត្រូវបង្ហាញភស្តុតាងសំរាប់បញ្ជាក់ថា ផលិតផលដែលដាក់លក់ទាំងនេះ ពិតជាបានបង់អាកររួចហើយនៅពេលបញ្ចូលក្នុងដែនដីនៃ ព្រះរាជាណាចក្រកម្ពុជា ។ បើគ្មានភស្តុតាងបញ្ជាក់ទេ ផ្នែកពន្ធដារត្រូវគិតគូរនិងទារប្រាក់អាករដែលត្រូវបង់ និងត្រូវអនុវត្តទោសទ័ណ្ឌជាធរមាន ។

## មាត្រា ២៨.-

វិធានច្បាប់ទាំងឡាយស្តីពីអាករលើផលរបរ ដែលប្រមូលនៅផ្ទៃក្នុងព្រះ

រាជាណាចក្រកម្ពុជា ដែលមិនផ្ទុយនឹងបទបញ្ញត្តិនៃជំពូកនេះ ត្រូវយកមកអនុវត្តចំពោះអាករពិសេសលើទំនិញផលិតឬធ្វើនៅកម្ពុជា ។

វិធានច្បាប់ទាំងនេះ គឺជាវិធានច្បាប់ចែងអំពីមូលដ្ឋានកំណត់ពន្ធ ការត្រួតពិនិត្យទោសបញ្ញត្តិ និងការប្រមូលពន្ធ ។

## មាត្រា ២៩.-

១. នីតិវិធីធម្មតានៃការកំណត់ពន្ធឡើងវិញ បន្ទាប់ពីការត្រួតពិនិត្យអាករពិសេសលើទំនិញមួយចំនួន ដែលប្រមូលដោយអង្គការពន្ធ គឺជានីតិវិធីដែលបានចែងនៅមាត្រា ២៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

២. នីតិវិធីនៃការកំណត់ពន្ធជាឯកតោភាគីរបស់អង្គការពន្ធអាចអនុវត្តបានចំពោះករណីទាំងឡាយ ដូចមានចែងនៅមាត្រា ៥៨ នៃច្បាប់ដូចយោងខាងលើ ។ នីតិវិធីដដែលនេះអាចអនុវត្តបានក្នុងករណីដែល បញ្ជីពិសេសដូចមានចែងក្នុងចំណុច ២ នៃមាត្រា ២៤ នៃច្បាប់នេះមិនបានបង្ហាញអោយឃើញ ។

## មាត្រា ៣០.-

បទបញ្ញត្តិនៃក្រឹត្យច្បាប់លេខ ២៤ ក្រ.ច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ ស្តីពីពន្ធលើទំនិញ ក្នុងប្រទេសដែលផ្ទុយនឹងបទបញ្ញត្តិកំណត់ក្នុងផ្នែកនេះ ត្រូវលុបចោលចាប់ពីពេលដែលច្បាប់នេះចូលជាធរមាន ។ រាល់ការកែប្រែដែលបានកំណត់ក្នុងផ្នែកនេះ ពុំមានអនុភាពប្រតិសកម្មទេ ។

# ផ្នែកទី ៣

## បទបញ្ញត្តិស្តីពីការកែប្រែការបង់ប្រចាំខែនូវប្រាក់រំដោះពន្ធលើ ប្រាក់ចំណេញ ដែលត្រូវបង់ដោយសហគ្រាសជាប់ពន្ធតាមរបបពិត

## មាត្រា ៣១.-

ចំពោះគ្រប់ប្រតិបត្តិការដែលសំរេចបានគិតចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៦ ចំនួនប្រាក់រំដោះ ត្រូវបង់ប្រចាំខែសំរាប់ពន្ធលើប្រាក់ចំណេញត្រូវកំណត់ ១% នៃផលរបរតិត្សូមបញ្ចូលទាំងអាករគ្រប់ប្រភេទ ដែលសំរេចបានក្នុងខែមុន ។ ប្រាក់រំដោះនេះនឹងត្រូវបានដកចេញពីចំនួនប្រាក់ពន្ធដែលត្រូវបង់នាពេលធ្វើការទូទាត់ប្រាក់ពន្ធជាស្ថាពរ ។

មាត្រា ៣២.-

ទោះបីលទ្ធផលសារពើពន្ធដែលបានធ្វើប្រកាសឬដែលបានទទួលស្គាល់យ៉ាងណាក្តី ប្រាក់ពន្ធ លើប្រាក់ចំណេញ ដែលត្រូវបង់ដោយសហគ្រាសជាប់ពន្ធតាមរបបពិតមិនត្រូវតិចជាងប្រាក់ពន្ធអប្បបរមា ដែលមានចំនួនស្មើនឹង ១% នៃផលរបរប្រចាំឆ្នាំ ដោយគិតរួមបញ្ចូលទាំងអាករគ្រប់ប្រភេទផង និងមិនអាចកាត់ ចេញពីប្រាក់រំលោះប្រចាំខែ សំរាប់ការិយបរិច្ឆេទបន្ទាប់ឬសងវិញឡើយ ។

បទបញ្ញត្តិស្តីពីពន្ធអប្បបរមា ដូចមានចែងនៅក្នុងមាត្រានេះ ត្រូវចាប់អនុវត្តជាលើកដំបូងសំរាប់ ពេលបិទការិយបរិច្ឆេទដែលចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៦ ។

---

# ជំពូកទី៥

## អវសានបញ្ញត្តិ

**មាត្រា ៣៤.-**

បទបញ្ញត្តិនៃច្បាប់ទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជា និរាករណ៍ ។

**មាត្រា ៣៥.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និង ទី២

**ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**នាយករដ្ឋមន្ត្រីទី១**

**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី២**

**ហ៊ុន សែន**